ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ទន្សោង
## រយៈពេល ៣ ឆ្នាំ (២០២០ - ២០២២)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ទន្សោង |
| ភូមិ | ៖ | ទន្សោង |
| ឃុំ | ៖ | សៀមបូក |
| ស្រុក | ៖ | សៀមបូក |
| ខេត្ត | ៖ | ស្ទឹងត្រែង |

ព្រះ[redacted]ណា[redacted]ក្រ[redacted]ម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ទន្សោង
# រយៈពេល ៣ ឆ្នាំ(២០២០ - ២០២២)

សហគមន៍នេសាទ ៖ ទន្សោង
ភូមិ ៖ ទន្សោង
ឃុំ ៖ សៀមបូក
ស្រុក ៖ សៀមបូក
ខេត្ត ៖ ស្ទឹងត្រែង

ខែមករា ឆ្នាំ២០១៩

# មាតិកា

**១.ស្ថានភាពទូទៅ** ...... ១
**២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម** ...... ២
ក.ប្រជាពលរដ្ឋ ...... ២
ខ.មុខរបរ ...... ២
**៣.កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ...... ២
ក.ទីតាំង ...... ២
ខ. ដែននេសាទ ...... ៣
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ...... ៣
ឃ.ធនធានជលផល ...... ៣
ឃ.១.ប្រភេទត្រីៈ ...... ៣
ឃ.២.ប្រភេទវារីសត្វៈ ...... ៤
ឃ.៣.ប្រភេទសត្វបក្សី ...... ៤
ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិៈ ...... ៤
**៤.ការធ្វើនេសាទ** ...... ៤
ក.អ្នកនេសាទ ...... ៤
ខ.ឧបករណ៍នេសាទ ...... ៤
គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ...... ៥
**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ...... ៦
ក.ទស្សនវិស័យ ...... ៦
ខ. គោលបំណងរួម ...... ៦
គ.គោលបំណងជាក់លាក់ ...... ៦
ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ...... ៦
ឃ.១.ធនធានជលផល និងអេកូឡូស៊ី ...... ៦
ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ...... ៦
ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ...... ៧
ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ...... ៧
ឃ.១.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក ...... ៨
ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ ...... ៨
ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល ...... ៨
ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ...... ៩
ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ...... ៩

ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ ........ ១០

ឃ.៣. ការងារគ្រប់គ្រង ........ ១០

ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ........ ១០

ឃ.៣.២.ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ........ ១០

ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ........ ១១

ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ១១

ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ ១១

ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ ១២

ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោមៈ ........ ១២

ច.យុទ្ធសាស្ត្រ ........ ១២

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទន្លោង រយៈពេល៣ឆ្នាំ (២០២០ ដល់ ២០២២)** ........ ១៤

**តារាងកម្មវិធីការងាររយៈពេល៣ឆ្នាំ(២០១៩ - ២០២២)** ........ ១៩

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

**១.ស្ថានភាពទូទៅ**

សហគមន៍នេសាទទន្សោង ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅឆ្នាំ១៩៩៧ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី២ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រយៈពេល៣ឆ្នាំគឺចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១។ សហគមន៍នេសាទនេះ មានទីតាំងស្ថិតនៅក្នុងភូមិទន្សោង ឃុំសៀមបូក ស្រុកសៀមបូក ខេត្តស្ទឹងត្រែង ដែលមានសមាជិកសរុបចំនួន៨១គ្រួសារ ស្មើនឹង១៨៥នាក់ ស្រីចំនួន៧៨នាក់ និងមានគណៈកម្មការចំនួន០៧នាក់ ស្រីចំនួន០៣នាក់។ សហគមន៍នេសាទទន្សោង ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយប្រកាសលេខ ៦២៨ ប្រក.កសក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមកសហគមន៍នេសាទបានអនុវត្តសកម្មភាពសំខាន់ៗ រួមមានដូចជាការរៀបចំបញ្ជីឈ្មោះ និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ ធ្វើបច្ចុប្បន្នភាពនិងរៀបចំបញ្ជីឈ្មោះសមាជិក លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ រៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ រៀបចំក្រុមល្បាត ព្រមទាំងចូលរួមប្រជុំ ចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗព្រមទាំងចុះល្បាតក្នុងកន្លែងនេសាទសហគមន៍ជាប្រចាំ។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងគឺ៖

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ី រួមមានការកាប់បំផ្លាញព្រៃលិចទឹក នាំឱ្យបាត់បង់ព្រៃលិចទឹកជាច្រើន ត្រីថយចុះគ្រប់ប្រភេទត្រី ការនេសាទនៅរដូវត្រីពងកូន បាក់ច្រាំងមាត់ទន្លេ និងកំណើនអ្នកនេសាទមកពីក្រៅសហគមន៍

-បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋរួមមាន ប្រជាពលរដ្ឋខ្វះមុខរបរចិញ្ចឹមជីវិត កំណើនប្រជាពលរដ្ឋ ខ្វះប្រភពទឹកធ្វើស្រែ ខ្វះចំណេះដឹងនិងជំនាញបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំ តម្លៃផលផលិតផលមិនស្ថិតស្ថេរ និងទីផ្សារនៅឆ្ងាយពីភូមិ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រងរួមមាន ការប្រើឧបករណ៍នេសាទខុសច្បាប់ (ការប្រើប្រាស់ឧបករណ៍ឆក់ និងប្រើសារជាតិពុល) ប្រជាពលរដ្ឋមិនហ៊ានរាយការណ៍ពេលឃើញបទល្មើស កិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធមិនទាន់រលូន មិនសូវមានការលើកទឹកចិត្តដល់គណកម្មការសហគមន៍នេសាទ ប្រជាពលរដ្ឋមិនយល់ពីសារៈប្រយោជន៍នៃសហគមន៍នេសាទ ខ្វះមធ្យោបាយចុះល្បាត និងថវិកា គ្មានទីស្នាក់ការសហគមន៍សម្រាប់ប្រតិបត្តិការ គណៈកម្មការសហគមន៍នេសាទពុំទាន់ស្គាល់ពីតួនាទីរបស់ខ្លួនហើយគណៈកម្មការសហគមន៍នេសាទ និងប្រជាជនមិនទាន់យល់ពីច្បាប់ស្តីពីជលផល លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ។

## ២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋក្នុងភូមិទន្សោងសរុប៤៩៣នាក់ ស្រី២៥៨នាក់ ស្មើនឹង៨៩គ្រួសារ ក្នុងនោះជនជាតិខ្មែរមាន៣២គ្រួសារ ស្មើហ្នឹង៣៦% នឹងជនជាតដើមភាគតិចកួយ ចំនួន៥៧គ្រួសារ ស្មើហ្នឹង៦៤% ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០%។

ប្រជាពលរដ្ឋក្នុងភូមិទន្សោង មានស្ថានភាពដូចខាងក្រោមះ

- ចំនួនស្ត្រីមេម៉ាយមាន ០៧ នាក់
- ចំនួនជនពិការមានប្រុស ០៥ នាក់ ស្ត្រី ០៣ នាក់
- ចំនួនក្មេងកំព្រាមានចំនួន ០២នាក់
- កម្រិតសិក្សាអប់រំមាន អ្នកមិនចេះអក្សរមានចំនួន១៦៥នាក់ ស្រី៧៤នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន៨៥ នាក់ ស្រី៤២ នាក់ កម្រិតអនុវិទ្យាល័យចំនួន០៨ នាក់ ស្រី០៦ នាក់ វិទ្យាល័យចំនួន ០១ នាក់ /ស្រី ០០ នាក់។

### ខ.មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានះ

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន ៨៩គ្រួសារ ត្រូវនឹង១០០%
- ធ្វើស្រែចំនួន៨៩ គ្រួសារ ដែលមានទំហំដីចំនួនសរុប ៤៣០ ហិកតា
- ដាំបន្លែជាលក្ខណៈគ្រួសារចំនួន៧០ គ្រួសារ / ដែលមានទំហំ ១ ហិកតា
- ជាងផ្ទះចំនួន ០២ គ្រួសារ
- ធ្វើចំការចំនួន៤២ គ្រួសារ ដែលមានទំហំដីចំនួនសរុប៨៥២ ហិកតា (ស្រូវ ពោត ចន្ទីរ សណ្តែក ល្ង ត្រសក់ ដំឡូងមី ទៅតាមរដូវកាល)
- លក់ដូរអាជីពចំនួន ១០ គ្រួសារ
- ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ៨៩គ្រួសារ ស្មើ១០០%
- រកអនុផលព្រៃឈើ៤៣ គ្រួសារ (ផ្សិត ឱសថបុរាណ វល្លិ ផ្តៅ ជ័រទឹក បន្លែព្រៃ ជ័រចុង ផ្លែឈើព្រៃ....)
- កែច្នៃផលនេសាទជាលក្ខណៈគ្រួសារចំនួនសរុប៨៩ គ្រួសារ (ធ្វើផ្អក ប្រហុក ត្រីប្រៃ ដែលមានចំនួនពី៥គីឡូក្រាមទៅ១០ គីឡូក្រាមក្នុងមួយឆ្នាំ។

## ៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក.ទីតាំង

កន្លែងនេសាទសហគមន៍ភូមិទន្សោង ជាដែននេសាទសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍ភូមិទន្សោង មានទំហំ ៤៣៧ ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

**មានព្រំប្រទល់ះ**

-ខាងជើងទល់នឹង កាំងរទេះ ជាប់ព្រំប្រទល់សហគមន៍នេសាទភ្លុល ឃុំកោះស្រឡាយ ស្រុកសៀមបូក

-ខាងកើតទល់នឹង ទន្លេកោះព្រះ ភូមិកោះព្រះ ឃុំកោះព្រះ ស្រុកសៀមបូក ខេត្តស្ទឹងត្រែង

-ខាងត្បូងទល់នឹង ពៀមអូរសៀមបូក ភូមិសៀមបូក ឃុំសៀមបូក ខេត្តស្ទឹងត្រែង

-ខាងលិចទល់នឹង ភូមិទន្សោង ឃុំសៀមបូក ស្រុកសៀមបូក ខេត្តស្ទឹងត្រែង។

ខ.ដែននេសាទ

កន្លែងសហគមន៍នេសាទទន្សោង មានវិសាលភាពនៅក្នុងទន្លេមេគង្គ ហើយមានប្រឡាយចំនួន៥ និងអន្លង់ចំនួន២។

ខ.១.ទន្លេមេគង្គ

| ឈ្មោះទន្លេ | ប្រវែង (ម៉ែត) | រដូវនេសាទ |
|---|---|---|
| ទន្លេមេគង្គ | ៤.២០០ | ពេញមួយឆ្នាំ |

ខ.២.ប្រឡាយ

| ឈ្មោះប្រឡាយ | ប្រវែង (ម៉ែត) | រដូវនេសាទនេសាទ |
|---|---|---|
| ប្រឡាយអូរជួរដី | ៧.០០០ | នេសាទបានពីខែ៦ដល់ខែ៨ |
| ប្រឡាយអូរខ្មោច | ៣.០០០ | នេសាទបានពីខែ៧ដល់ខែ៩ |
| ប្រឡាយអូរទន្សោង | ៦.០០០ | នេសាទបានពីខែ៧ដល់ខែ៩ |
| ប្រឡាយអូកាំងចង្អេ | ១.០០០ | នេសាទបានពីខែ៨ដល់ខែ៩ |
| ប្រឡាយអូរតាអ៊ុង | ២.០០០ | នេសាទបានពីខែ៧ដល់ខែ៩ |

ខ.៣.អន្លង់

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់កាំងចង្អេរ | ១០០ x ១០០ | ១០.០០០ | ២៥ | ១៥ |
| អន្លង់យាយកែវ | ២០០ x ៣០០ | ៦០.០០០ | ៣០ | ២០ |

គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សចំនួន០១អន្លង់គឺអន្លង់យាយកែវ តាមការសម្រេចរបស់មហាសន្និបាតសហគមន៍នេសាទទន្សោង។

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | ទំហំសរុប (ហិកតា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់យាយកែវ | ២០០ x ៣០០ | ៦០.០០០ | ៣០ | ២០ |

ឃ.ធនធានជលផល

ឃ.១.ប្រភេទត្រី

ត្រីរស់ ឆ្តោរ រៀល ស្លាត ឆ្លាំង ក្រម៉ម អណ្តែង ច្រវ៉ា កំភ្លាញ ឆ្លូញ ខ្នាន់ ឆ្ពិន ច្រកែងកន្ទ្រប់ ត្រីដំរី កញ្ចុះ ក្រុះ កញ្ច្រូកកាហែរ ត្រីលិញ ត្រនេល សណ្តាយ ក្រាយ ព្រលូង ត្រីស្លឹកឬស្សី ត្រីខ្ញឹង ត្រីខ្យា ត្រីកេះ ឆ្ពោក ត្រីកែ ត្រីត្រសក់ ត្រីគល់រាំង ត្រីអណ្តែង ត្រីក្អែក ត្រីថ្ម ត្រីចិន ត្រីបបែល ត្រីពោ ត្រីចេកទុំ ត្រីក្លាំងហាយ ត្រីឆ្មា ត្រីរាហ៊ូ ត្រីក្របី ត្រីកន្ត្រងប្រេង ត្រីឬស្សីចេក ត្រី

ក្អុក ត្រីគ្រំ ត្រីកំបុតច្រមុះ ត្រីខ្យាថ្ម ត្រីប៉ាស៊ីអ៊ី ត្រីប៉ាវ៉ា ត្រីអន្លង់ ត្រីអាចម៍កុក។

**ឃ.២.ប្រភេទវារីសត្វ៖**

ក្ដាម ខ្យង ខ្ចៅ គ្រុម លៀស អណ្ដើក កន្ធាយ ពស់ កំពិស កង្កែប ហ៊ីង គីង្គក់។

**ឃ.៣.ប្រភេទបក្សី៖**

កុកស កុកក្រក មាន់ទឹក មាន់ ប្រវឹក ទាព្រៃ រនាលខ្យង ក្រសារ ខ្លោត្រី ក្អែកទឹក ក្អែកគោក។

**ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖**

ដើមត្រែង ដើមអញ្ចែង ដើមរំចេក ដើមអណ្ដែង ដើមត្រស់ ដើមរាំង ដើមល្វា ដើមផ្ទាទឹក ដើមព្រុះទឹក ដើមបន្លាឃ្លេ។

## ៤.ការធ្វើនេសាទ

**ក.អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៨១គ្រួសារ ស្មើ១៦២នាក់ ស្ត្រី៨១នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទមានចំនួន ៨គ្រួសារ ស្មើ២៤នាក់ ស្ត្រី១០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន១០ គ្រួសារ ០១ថ្ងៃចំនួន១០នាក់ ស្រី០៥នាក់។

**ខ.ឧបករណ៍នេសាទ**

ឧបករណ៍នេសាទ និងទូកការណូតរបស់សមាជិកសហគមន៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ ឧបករណ៍ នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | |
| សន្ទូចរនង | ផ្លែ | ៨៩គ្រួសារ× ១០០ផ្លែ=៨. ៩០០ ផ្លែ | ៨គ្រួសារ× ១០០ផ្លែ= ៨ ០០ផ្លែ | ៥គ្រួសារ× ២០០ផ្លែ= ១.០០០ផ្លែ | ផ្លែលេខ១២ ដល់០៥ | ផ្លែលេខ១២ ដល់០៥ | ផ្លែលេខ១២ ដល់០៥ | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ២០គ្រួសារ x ២ =៤០វង់ | ៨គ្រួសារ×២ វង់=១៦វង់ | ៥គ្រួសារx១ =៥វង់ | សំរុង៣,៥០ -៥.៥០ម | សំរុង៣,៥០ - ៥,៥០ម | សំរុង៣,៥០ - ៥,៥០ម | ពេញមួយឆ្នាំ |
| ចាន់ | គ្រឿង | ៣៥គ្រួសារ×២ គ្រឿង=៧០ គ្រឿង | ៨គ្រួសារ× ២គ្រឿង= ១៦ គ្រឿង | គ្មាន | មុខកាត់០,៣ ម បណ្ដោយ ៦០ស.ម | មុខកាត់០,៣ ម បណ្ដោយ ៦០ស.ម | គ្មាន | ខែ៨-១០ |
| លប | គ្រឿង | ៤៥គ្រួសារx២ គ្រឿង=៩០ គ្រឿង | ៨គ្រួសារ× ២គ្រឿង= ១៦គ្រឿង | គ្មាន | មុខកាត់០,៣ ម បណ្ដោយ ១,៥០ម | មុខកាត់០,៣ មបណ្ដោយ ១,៥០ម | | ខែ៨-១០ |
| ទ្រូ | គ្រឿង | ៣៥គ្រួសាx៣ =១០៥គ្រឿង | ៨គ្រួសាx៣ =២៤គ្រឿង | គ្មាន | មុខកាត់៤ស. មប្រវែង១ម | មុខកាត់៤ស .មប្រវែង១ម | គ្មាន | ខែ៨-១០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| សៃយឺន | គ្រឿង | ១៥គ្រួសារx៣ =៤៥ គ្រឿង | ៨គ្រួសារ×២ គ្រឿង=១៦ គ្រឿង | គ្មាន | មុខកាត់១,៧ ម បណ្តោយ ២ម | មុខកាត់១,៧ ម បណ្តោយ ២ម | គ្មាន | ខែ៨-១១ |
| ឈ្នាងជញ្ជាត់ | គ្រឿង | ៥គ្រួសារx១ =៥ គ្រឿង | គ្មាន | គ្មាន | ទំហំ០,៣-០,៥មប្រវែង១ម | គ្មាន | គ្មាន | ខែ៧-១១ |
| ស្នូរ | គ្រឿង | ១០គ្រួសារx ១=១០គ្រឿង | ៤គ្រួសារx ១=៤គ្រឿង | គ្មាន | ទំហំផ្លែ០,៣ ប្រវែង១,៥ម | ទំហំផ្លែ០,៣ ប្រវែង១,៥ម | គ្មាន | ខែ៧-១១ |
| សន្ទូចរាត់ | ផ្លែ | ៨៩គ្រួសារx ៥០=៤.៤៥០ ផ្លែ | គ្មាន | គ្មាន | ផ្លែលេខ១២ ដល់០៥ | គ្មាន | គ្មាន | ខែ៧-១១ |

ប្រភេទកាណូត

| ប្រភេទទូកកាណូត | ចំនួន (គ្រឿង) | | | ចំណុះ (គីឡូក្រាម) | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកអេរវជាប់ម៉ាស៊ីនHONDA | ៣៨ | ៨ | ១០ | ៣០០-៥០០ | ១០០-៣០០ | ៣០០ - ៥០០ | ៥-៥-៧-១៣ | ៥-៥-៧-១៣ | ១៣ |
| ទូកដឹកទំនិញ | ៣ | ០ | ០ | ១តោន | ០ | ០ | ១២៥ | ០ | ០ |
| ទូកអុំ ទូកចែវ | ៣ | ២ | ០ | ១០០ | ២០០-៣០០ | ០ | ០ | ០ | ០ |

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៧៤១,១៤ | ៩១៩,៩១ | ១.៦៦១,០៥ |
| សរុប | | | **១.៦៦១,០៥** |

## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទទន្លេរាងមានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ.គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនៈវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ។

### គ.គោលបំណងជាក់លាក់

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប កន្លែងនេសាទគ្រួសារដែលរក្សាទុក សម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋ ខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

### ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### ឃ.១.ធនធានជលផល និងអេកូឡូស៊ី

#### ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទឧបករណ៍នៅក្នុងដែននេសាទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ក្នុងទន្លេមេគង្គកន្លែងនេសាទសហគមន៍ទន្លេរាង | នេសាទពេញ១ឆ្នាំជាលក្ខណៈគ្រួសារ | សំណាញ់ | ជម្រៅ៣-៥ម ក្រឡា២-១២ហ៊ុន | ២វង់/គ្រួសារ | សមាជិកសហគមន៍ អ្នកនេសាទខាងក្នុង និងអ្នកនេសាទខាងក្រៅសហគមន៍ |
| | | លប | មុខកាត់០,៨០ម×១,៥ម | ២គ្រឿង/គ្រួសារ | |
| | | ចាន់ | មុខកាត់៣០-៥០ស.ម ប្រវែង១ម | ៥គ្រឿង/គ្រួសារ | |
| | | សៃយ៉ឺន | មុខកាត់១,៧ម បណ្តោយ២.៥ម | ៣គ្រឿង/គ្រួសារ | |
| | | ទ្រូ | មុខកាត់៤០ស.ម ប្រវែង១ម | ៣គ្រឿង/គ្រួសារ | |
| | | ឈ្នាងជញ្ជាត់ | មុខកាត់១,៥ស.ម ប្រវែង២ម | ១គ្រឿង/គ្រួសារ | |
| | | សន្ទូចរនង | ផ្លែលេខ២០ ដល់០៥ | ១០០ផ្លែ/គ្រួសារ | |
| | | ស្ទូរ | ទំហំផ្លែ០,៣ ប្រវែង១,៥ម | ១គ្រឿង/គ្រួសារ | |
| | | សន្ទូចរាត់ | ផ្លែលេខ២០ ដល់០៥ | ៥០ផ្លែ/គ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| -អួរជួរដី<br>-អួរខ្មោច<br>-អួរទន្លេរាង<br>-អួរកាំងចង្កេ -<br>អួរតាអ៊ឹង | ខែ៨ - ខែ១១ | សំណាញ់ | ជម្រៅ៣-៥ម ក្រឡា២-១២ហ៊ុន | ២វង់/គ្រួសារ | សមាជិកសហគមន៍នេសាទទន្លេរាង |
| | | លប | មុខកាត់០,៨០ម×១,៥ម | ២គ្រឿង/គ្រួសារ | |
| | | ចាន់ | មុខកាត់៣០-៥០ស.ម ប្រវែង១ម | ៥គ្រឿង/គ្រួសារ | |
| | | សៃយ៉ឹន | មុខកាត់១,៧ម បណ្តោយ២,៥ម | ៣គ្រឿង/គ្រួសារ | |
| | | ទ្រូ | មុខកាត់៤០ស.ម ប្រវែង១ម | ៣គ្រឿង/គ្រួសារ | |
| | | ឈ្នាងជញ្ជាត់ | មុខកាត់១,៥ស.ម ប្រវែង២ម | ១គ្រឿង/គ្រួសារ | |
| | | សន្ទូចរនង | ផ្លែលេខ២០ ដល់០៥ | ១០០ផ្លែ/គ្រួសារ | |
| | | ស្ទូរ | ទំហំផ្លែ០,៣ ប្រវែង១,៥ម | ១គ្រឿង/គ្រួសារ | |
| | | មង | ជម្រៅ ៣ ម៉ែត្រ ក្រឡា០២-០៧ស.ម | ១០០ម៉ែត្រ/គ្រួសារ | |

### ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ

ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ/ចំនួន | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | បញ្ចប់ |
| កន្លែងនេសាទសហគមន៍ទន្លេរាង | បង្គោលព្រំធ្វើពីស៊ីម៉ង់ចំនួន៦បង្គោល | -ផលិតបង្គោលព្រំចំនួន៦បង្គោល<br>-រៀបចំក្រុមបោះបង្គោល(ដោយមានការសម្រេចចិត្តគណៈកម្មការ)<br>-ផ្សព្វផ្សាយជាសាធារណៈ | ៥០០ | -គណៈកម្មការ<br>-សមាជិកស.ន<br>-គណៈកម្មការ | ២០២០ | ២០២២ |
| | ផ្ទាំងប៉ាណូផែនទីចំនួន២ | ផលិត និងបោះផ្ទាំងប៉ាណូផែនទី | ៥០០ | គណៈកម្មការ | ២០២០ | ២០២០ |
| | ស្លាកអប់រំ ៣០ | ផលិតស្លាកអប់រំ ចុះបោះស្លាកកន្លែងសហគមន៍ | ១២០ | គណៈកម្មការ | ២០២០ | ២០២០ |

### ឃ.១.៣.ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សត្រូវបានរៀបចំដូចខាងក្រោមៈ

| ឈ្មោះ | ទំហំ (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់យាយកែវ | ៦ | -ត្រីមេពូជ<br>-សត្វស្លាប<br>-ព្រៃលិចទឹកគ្រប់ | -ផ្សព្វផ្សាយពីកន្លែងអភិរក្ស<br>-បោះទង់សំគាល់ព្រំតំបន់អភិរក្សចំនួន ៤បង្គោល<br>-ដាក់ស្លាកសញ្ញាសម្គាល់ចំនួន ៣០ ស្លាក<br>-ចុះល្បាតការពារជាប្រចាំ | ៥៥០ | ២០២០ | ២០២២ |

### ឃ.១.៤.ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ (ហិកតា) | ប្រភេទកូនឈើការពារ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| នៅក្នុងដែនសហគមន៍នេសាទទន្សោង | ២ | ព្រៃលិចទឹកចម្រុះ | - ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈប្រយោជន៍ព្រៃលិចទឹក<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក<br>- ថែរក្សា ការពារព្រៃលិចទឹកចម្រុះ<br>- ចុះល្បាតការពារជាប្រចាំ | ៥០០ | ២០២០ | ២០២២ |

### ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ

### ឃ.២.១.ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំឡើងដូចខាងក្រោម

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|
| ៣០គ្រួសារចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | -ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់<br>-អនុវត្តជាក់ស្តែង និងធ្វើទ្រុង ផ្តល់ពូជ<br>-ចុះតាមដាន ត្រួតពិនិត្យ | ពូជក្នុងស្រុក | ៣.៥០០ | ២០២០ | ២០២២ |
| ១៥គ្រួសារបង្កើតធនាគារក្របី | - ប្រជុំផ្សព្វផ្សាយ ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- បង្កើតគោលការណ៍ក្រុម<br>- ជ្រើសរើសគ្រួសារ និងផ្តល់មេក្របី<br>- តាមដានត្រួតពិនិត្យការថែទាំ | ពូជក្នុងស្រុក | ២.៥០០ | ២០២០ | ២០២២ |
| ៣០គ្រួសារចិញ្ចឹមជ្រូកតាម បច្ចេកទេសជាលក្ខណៈគ្រួសារ | - ប្រជុំផ្សព្វផ្សាយ ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- រៀបចំទ្រុងសម្រាប់ចិញ្ចឹម<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- រកទិញពូជ និងដាក់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យការថែទាំ | កូនជ្រូកពូជ ៣០ក្បាល | ៣.០០០ | ២០២០ | ២០២២ |

| | | | | | |
|---|---|---|---|---|---|
| ដាំបន្លែតាមបច្ចេកទេសកសិកម្មវ័យឆ្លាត | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- វគ្គបណ្តុះបណ្តាលបច្ចេកទេសដាំបន្លែ<br>- ផ្តល់គ្រាប់ពូជបន្លែ<br>- តាមដានត្រួតពិនិត្យ | គ្រាប់បន្លែ(ស្ពៃគ្រប់,ត្រកួន ត្រសក់,សណ្តែកគួរ | ១.៥០០ | ២០២០ | ២០២២ |
| បង្កើតក្រុមសន្សំប្រាក់១ក្រុម(មានសមាជិក៣០នាក់) | - ផ្សព្វផ្សាយទស្សនៈក្រុមសន្សំ<br>- រៀបចំបោះឆ្នោតរើស គណៈកម្មការ<br>- រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង<br>- បណ្តុះបណ្តាលគណៈកម្មការក្រុម<br>- ប្រជុំបូកសរុបប្រាក់សន្សំប្រចាំខែ<br>- ត្រួតពិនិត្យតាមដានជាប្រចាំ | សមាជិកក្នុងសហគមន៍នេសាទ | ១.០០០ | ២០២០ | ២០២២ |
| ពង្រឹងធនាគារស្រូវក្នុងភូមិឡើងវិញ | - បង្កើតគោលការណ៍សារថ្មី<br>- រៀបចំគណៈកម្មការក្រុមថ្មី<br>- តាមដានត្រួតពិនិត្យជាប្រចាំខែ | ក្រុមធនាគារស្រូវដែលមានស្រាប់ | ៥០០ | ២០២០ | ២០២២ |

### ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណកូនត្រី | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | បញ្ចប់ |
| ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសលក្ខណៈគ្រួសារ ១៥គ្រួសារ | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- រៀបចំស្រះ ដាក់កូនត្រី<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- ត្រួតពិនិត្យ ធ្វើសំណាក | ៥ស្រះ ទំហំ ៨ម×៧ម | ៨០០ក្បាលក្នុង១គ្រួសារ | ៧.៥០០ | ២០២០ | ២០២២ |

### ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| សាងសង់អណ្តូងស្នប់ចំនួន២អណ្តូង | ២.០០០ | ២០២០ | ២០២២ |
| សាងសង់បង្គន់អនាម័យក្នុងសហគមន៍ ចំនួន៣០ គ្រួសារ | ៦.០០០ | ២០២០ | ២០២២ |
| បង្កើតឡជីវឧស្ម័នដល់សមាជិកសហគមន៍ ចំនួន០៥ គ្រួសារ | ៩.០០០ | ២០២០ | ២០២២ |
| ផ្តល់ផ្ទាំងសូឡាពន្លឺព្រះអាទិត្យ ចំនួន ៣៥គ្រួសារ | ៨.៧៥០ | ២០២០ | ២០២២ |
| ផ្តល់ធុងចម្រោះទឹក ចំនួន៥០គ្រួសារ (៥០ ធុង) | ១.២៥០ | ២០២០ | ២០២២ |

### ឃ.២.៤. ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ

ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ផែនការបង្ការ និងបន្សាំភាព ធន់និងការប្រែប្រួលអាកាសធាតុ | -ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួល អាកាសធាតុ និងការបង្ការ<br>-រៀបចំបង្គោលវាស់កម្ពស់ទឹក<br>-កំណត់ រៀបចំទីទួលសុវត្ថិភាព<br>-ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ និងចងក្រងបណ្តាញក្រុមទ្រទ្រង់គ្រោះមហន្តរាយ<br>-ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការបន្សាំការប្រែប្រួលអាកាសធាតុ | ៧០០ | ២០២០ | ២០២២ | |

### ឃ.៣.ការងារគ្រប់គ្រង

### ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ប៉ាន់ប្រមាណ ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| សហគមន៍នេសាទចុះល្បាតដោយខ្លួនឯង | ៣ដង/១ខែ | ១.០៨០ | ២០២០ | ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | ២ដង/១ខែ | ៤.៥០០ | ២០២០ | ២០២២ |
| ទិញទូកស្ពាច់ និងម៉ាស៊ីន (១៣សេះ) | ១ គ្រឿង | ១.២០០ | ២០២០ | ២០២២ |
| ប្រេងសម្រាប់ចុះល្បាត | ៥០លីត្រ/ខែ | ១.៨០០ | ២០២០ | ២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍ | ១ កន្លែង | ៣.០០០ | ២០២០ | ២០២២ |

### ឃ.៣.២.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ត្រូវរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| រៀបចំប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១២ដង/ឆ្នាំ | ៣៨០ | ២០២០ | ២០២២ |
| ចូលរួមប្រជុំប្រចាំខែ ឬត្រីមាស ជាមួយក្រុមប្រឹក្សាឃុំ | ១២ដង/ឆ្នាំ | ៣៨០ | | |
| បណ្តុះបណ្តាលការរៀបចំរបាយការណ៍ កំណត់ហេតុ | ១ដង/ឆ្នាំ | ២៥០ | | |

| | | | | |
|---|---|---|---|---|
| បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ១ដង/ឆ្នាំ | ២៥០ | | |
| បណ្តុះបណ្តាលសរសេរគម្រោងសំណើរ | ១ដង/ឆ្នាំ | ២៥០ | | |
| ទស្សនៈកិច្ចសិក្សាក្រៅខេត្តផ្លាស់ប្តូរបទពិសោធន៍ | ១ដង/ឆ្នាំ | ១.០០០ | | |

### ឃ.៣.៣.ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សាមជិកសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួនដង | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ | ២ដង/ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ៦០០ | | |
| ច្បាប់ស្តីពីជលផល តំបន់ការពារធម្មជាតិ | ២ដង/ឆ្នាំ | ៦០០ | | |
| យុទ្ធនាការផ្សព្វផ្សាយ ប្រមូលឧបករណ៍នេសាទខុសច្បាប់ និងដុតបំផ្លាញ | ១ដង/ឆ្នាំ | ១៥០ | | |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្រ្តីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ | ៦០០ | | |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ៣០០ | ២០២០ | ២០២២ | - គណៈកម្មាការសហគមន៍នេសាទ<br>- អាជ្ញាធរឃុំ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | | ២០២០ | ២០២២ | |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | ចុះប្រមូលប្រាក់សមាជិកភាព ៥០០៛ | ២០២០ | ២០២២ | ២៣,១២៥ | |

| | | | | | |
|---|---|---|---|---|---|
| ភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍នេសាទ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ ចំនួន ២.០០០/គ្រួសា នៃសមាជិកសរុប | ២០២០ | ២០២២ | ១៣៣,៥០ (៣ឆ្នាំ) | |
| ភាគទានពីអ្នកនេសាទក្រៅសហគមន៍នេសាទ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទក្រៅចំនួន៣០នាក់(១០.០០០រៀល/ទូក/រដូវនេសាទ) | ២០២០ | ២០២២ | ២.៧០០ | |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិកសហគមន៍នេសាចំនួន៨នាក់ (១០.០០០រៀល/ទូក/រដូវនេសាទ) | ២០២០ | ២០២២ | ៧២០ | |
| បដិភាគពីក្រុមសន្សំប្រាក់ | ភាគលាភពីក្រុមសន្សំប្រាក់ | ២០២០ | ២០២២ | **២២,៥០** | |
| **សរុបថវិការបស់សហគមន៍** | | | | **៣.៨០៧** | |
| **ប្រាក់ចំណូលពីប្រភពផ្សេងៗ** (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែន រដ្ឋាភិបាល និងអំណោយពីសប្បុរសជន) | បញ្ចូលផែនការអភិវឌ្ឍសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ | ២០២០ | ២០២២ | **៦២.៤២៣** | |
| | ទំនាក់ទំនងជាមួយស្ថាប័នជលផល | ២០២០ | ២០២២ | | |
| | សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ២០២០ | ២០២២ | | |
| **សរុប** | | | | ៦៦.២៣០ | |

**ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**

ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖

| **សកម្មភាព** | **ប៉ាន់ប្រមាណថវិកា(ដុល្លារ)** | **ថ្ងៃខែឆ្នាំចាប់ផ្តើម** | **ថ្ងៃខែឆ្នាំបញ្ចប់** | **អ្នកទទួលខុសត្រូវ** |
|---|---|---|---|---|
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិច និងអ្នកពាក់ព័ន្ធ | ៣០០ | ២០២០ | ២០២២ | -គណៈកម្មការ<br>-អាជ្ញាធរឃុំ |

**ច.យុទ្ធសាស្រ្ត**

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្រ្តមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម

- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍នេសាទ
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការគ្រប់គ្រង
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ។

## តារាងសង្ខេបផែនការគ្រប់ ទកន្លែងនេសាទសហគមន៍នេសាទរយៈពេល ៣ ( ំ ( ២០២០ ដល់ ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.១.ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ២ដង ក្នុង១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ៦០០<br>១ដង×១០០×២លើក×៣ឆ្នាំ | -សហគមន៍នេសាទ<br>-រដ្ឋបាលជលផល<br>-អង្គការដៃគូ | ២០២០ | ២០២២ | |
| ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | ផលិតបង្គោលព្រំចំនួន៦បង្គោល | - បង្គោលព្រំចំនួន៦ដើម ត្រូវបានផលិត និងបានបោះនៅតាមព្រំប្រទល់ដែននេសាទ<br>- កាត់បន្ថយបាននូវទំនាស់ព្រំប្រទល់ | ៥០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | ដំឡើងផ្ទាំងប៉ាណូផែនទី និងរូបភាពផ្សព្វផ្សាយចំនួន២ផ្ទាំង | ផ្ទាំងប៉ាណូផែនទីចំនួន២ផ្ទាំងបានផលិត និងបានបោះនៅក្នុងសហគមន៍ | ៥០០ | | ២០២០ | ២០២២ | |
| | ផលិតស្លាកអប់រំដាក់នៅក្នុងសហគមន៍និងតាមដងទន្លេ | ស្លាកអប់រំចំនួន៣០ត្រូវបានផលិតនិងបានបោះនៅតាមសហគមន៍/តាមទន្លេ | ១២០ | | ២០២០ | ២០២២ | |
| ឃ.១.៣.ការកំណត់ និងរៀបចំតំបន់អភិរក្សអន្លង់យាយកែវ | - ផ្សព្វផ្សាយពីកន្លែងអភិរក្សនិងសារៈប្រយោជន៍កន្លែងអភិរក្ស<br>- បោះទង់សំគាល់ព្រំតំបន់អភិរក្ស<br>- ដាក់ស្លាកនៅតំបន់អភិរក្ស៣០ស្លាក<br>- ចុះល្បាតការពារជាប្រចាំ | - ត្រី និងសត្វគ្រប់ប្រភេទ នឹងសំបូរឡើងវិញនៅក្នុងតំបន់សហគមន៍<br>-ប្រជាជនយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស និងបានដឹងពីព្រំប្រទល់កន្លែងអភិរក្សនិងចូលអភិរក្ស។ | ៥៥០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| ឃ.១.៤.ផែនការគ្រប់គ្រងការពារព្រៃលិចទឹក | - ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈប្រយោជន៍ព្រៃលិចទឹក<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក | ព្រៃលិចទឹកកើនឡើងវិញធនធានត្រីមានការកើនឡើងវិញ | ៥០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | - ថែរក្សា ការពារព្រៃលិចទឹកចម្រុះ<br>- ចុះល្បាតការពារជាប្រចាំ | | | | | | |
| ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| ឃ.២.១.ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមមាន់តាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមមាន់ ចំនួន៣០គ្រួសារ | ៣.៥០០ | -រដ្ឋបាលជលផល<br>-អង្គការដៃគូ | ២០២០ | ២០២២ | |
| | បង្កើតធនាគារក្របី | មានគ្រួសារចំនួន១៥គ្រួសារបានបង្កើត | ២.៥០០ | | ២០២០ | ២០២២ | |
| | ចិញ្ចឹមជ្រូកតាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមជ្រូកចំនួន៣០គ្រួសារ | ៣.០០០ | | ២០២០ | ២០២២ | |
| | ដាំបន្លែតាមបច្ចេកទេសកសិកម្មវ័យឆ្លាត | មានគ្រួសារដាំបន្លែចំនួន៣០ គ្រួសារ | ១.៥០០ | | ២០២០ | ២០២២ | |
| | បង្កើតក្រុមសន្សំប្រាក់១ក្រុម | មានសមាជិកចូលរួមចំនួន១៥នាក់ | ១.០០០ | | ២០២០ | ២០២២ | |
| | ពង្រឹងធនាគារស្រូវក្នុងភូមិ | ធនាគារស្រូវត្រូវបានពង្រឹងឡើងវិញ | ៥០០ | | ២០២០ | ២០២២ | |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមត្រីអណ្តែងចំនួន១៥គ្រួសារ | ៧.៥០០ | -រដ្ឋបាលជលផល<br>-អង្គការនានា | ២០២០ | ២០២២ | |
| ឃ.២.៣. ផែនការសេវាសហគមន៍និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច | បង្កើតឡជីវឧស្ម័នដល់សមាជិក | ឡជីវឧស្ម័ន ចំនួន៥គ្រួសារ | ៩.០០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | សាងសង់បង្គន់អនាម័យ | មានបង្គន់អនាម័យចំនួន៣០បង្គន់ | ៦.០០០ | | ២០២០ | ២០២២ | |
| | សាងសង់អណ្តូងស្នប់ | មានអណ្តូងស្នប់ ២អណ្តូង | ២.០០០ | | ២០២០ | ២០២២ | |
| | ផ្តល់ធុងចម្រោះទឹក | មានធុងចម្រោះចំនួន៥០ធុង | ១.២៥០ | | ២០២០ | ២០២២ | |
| | ផ្តល់ផ្ទាំងសូឡាពន្លឺព្រះអាទិត្យ | ៣៥គ្រួសារទទួលបានផ្ទាំងសូឡា | ៨.៧៥០ | | ២០២០ | ២០២២ | |
| ឃ.២.៤.ផែនការបង្ការនិងបន្សាំការប្រែប្រួល | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួល អាកាសធាតុ និងការបង្ការ | គណៈកម្មការ និងសមាជិកមានការយល់ដឹងពីផលប៉ះពាល់ពីការប្រែ | ១០០ | -រដ្ឋបាលជលផល<br>-អង្គការនានា | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| អាកាសធាតុ | | ប្រូលអាកាសធាតុ និងរបៀបបង្ការ | | -សប្បុរសជន | | | |
| | រៀបចំបង្គោលវាស់កម្ពស់ទឹក | មានបង្គោលវាស់កំពស់ទឹកចំនួន១ | ២០០ | | ២០២០ | ២០២២ | |
| | កំណត់ រៀបចំទីទួលសុវត្ថិភាព | មានកន្លែងទីទួលសុវត្ថភាពចំនួន១ | ១០០ | | ២០២០ | ២០២២ | |
| | ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ និងចងក្រងបណ្តាញក្រុមទ្រទ្រង់គ្រោះមហន្តរាយ | មានគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ និងបានចងក្រងបណ្តាញ | ១០០ | | ២០២០ | ២០២២ | |
| | ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការបន្សាំការប្រែប្រួលអាកាសធាតុ | គណៈកម្មការមានចំណេះដឹងទាក់ទងនិងការប្រែប្រួលអាកាសធាតុ | ២០០ | | ២០២០ | ២០២២ | |
| ឃ.៣. ការងារគ្រប់គ្រង | | | | | | | |
| ឃ.៣.១.ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | សហគមន៍ចុះល្បាតដោយខ្លួនឯង | បានចុះល្បាត៣ដង/ខែ | ១.០៨០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | បានចុះល្បាត២ដង/១ខែសហការជាមួយអាជ្ញាធរមូលដ្ឋាន | ៤.៥០០ | | ២០២០ | ២០២២ | |
| | ទិញទូកស្ពាច់ម៉ាស៊ីន (១៣សេះ) | មានទូកម៉ាស៊ីន ចំនួន១គ្រឿង | ១,២០០ | | ២០២០ | ២០២២ | |
| | ប្រេងសម្រាប់ចុះល្បាត | ៥០លីត្រ/១ខែ | ១,៨០០ | | ២០២០ | ២០២២ | |
| | សាងសង់ទីស្នាក់ការសហគមន៍នេសាទ | មានស្នាក់ការ១ខ្នងសម្រាប់សហគមន៍នេសាទធ្វើការងារ | ៥០០ | | ២០២០ | ២០២២ | |
| ឃ.៣.២. ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | បានប្រជុំ១ដង/១ខែ ជាមួយគណៈកម្មការ សមាជិកក្នុងសហគមន៍ | ៣៤០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល | ២០២០ | ២០២២ | |
| | ចូលរួមប្រជុំប្រចាំខែជាមួយឃុំ | ចូលរួម១ដង/១ខែជាមួយ ឃុំ | ៣៤០ | -អាជ្ញាធរឃុំ | ២០២០ | ២០២២ | |
| | បណ្តុះបណ្តាលការរៀបចំរបាយការណ៍ កំណត់ហេតុ | -មានវគ្គបណ្តុះបណ្តាលលើមុខជំនាញនីមួយៗ១លើក/១ឆ្នាំ | ២៥០ | -សហគមន៍នេសាទ | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | បណ្ដុះបណ្ដាលអំពីការគ្រប់គ្រងថវិកា | -សមត្ថភាពគណៈកម្មការបានល្អ<br>-គណៈកម្មការអាចអនុវត្តន៍បាន | ២៥០ | | ២០២០ | ២០២២ | |
| | បណ្ដុះបណ្ដាលការសរសេរគម្រោងសំណើ | | ២៥០ | | ២០២០ | ២០២២ | |
| | ទស្សនកិច្ចសិក្សាផ្លាស់ប្ដូរបទពិសោធន៍ | គណៈកម្មការទទួលបាននូវចំនេះដឹង និងបទពិសោធន៍ល្អ | ១.០០០ | | ២០២០ | ២០២២ | |
| ឃ.៣.៣.ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរឃុំ<br>-សហគមន៍នេសាទ | ២០២០ | ២០២២ | |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀង | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | | ២០២០ | ២០២២ | |
| | ផ្សព្វផ្សាយច្បាប់ស្ដីពីជលផលនិងបទដ្ឋាន បច្ចេកទេសពាក់ព័ន្ធ | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | | ២០២០ | ២០២២ | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងពីសារៈប្រយោជន៍ធនធានជលផល និងការប្រមូលឧបករណ៍នេសាទខុសច្បាប់ និងដុតបំផ្លាញ | បានរៀបចំយុទ្ធនាការ១ដង/ឆ្នាំ | ១៥០ | | ២០២០ | ២០២២ | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្រ្តីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាព និងសមធម៌យេនឌ័រ | បានរៀបចំកិច្ចប្រជុំ១ដង/ឆ្នាំ | ៦០០ | | ២០២០ | ២០២២ | |
| ឃ.៣.៤.ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | -បានផ្សព្វផ្សាយ ២ដង/ឆ្នាំ<br>-បានបញ្ចូលសកម្មភាពផែនការគ្រប់គ្រងរបស់សហគមន៍នេសាទទៅក្នុងផែនការកម្មវិធីវិនិយោគឃុំ | ៣០០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរឃុំ | ២០២០ | ២០២២ | |
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | | | | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.៣.៥.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ | ភាគទានពីសមាជិកភាព | សមាជិកសហគមន៍បានបង់ភាគទានសមាជិកភាព ៥០០៛ /នាក់ | ២៣,១២៥ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរមូលដ្ឋាន | ២០២០ | ២០២២ | |
| | ភាគទានពីសមាជិកប្រចាំឆ្នាំ | សមាជិកសហគមន៍បានបង់ភាគទានប្រចាំឆ្នាំ១ឆ្នាំម្តង ២.០០០៛/គ្រួសារ | ១៣៣,៥០ | | ២០២០ | ២០២២ | |
| | ភាគទានពីអ្នកខាងក្រៅ និងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមកពីខាងក្រៅ១០.០០០/ទូក/ថ្ងៃ | ២.៧០០ | | ២០២០ | ២០២២ | |
| | | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ | ៧២០ | | ២០២០ | ២០២២ | |
| | បដិភាគពីក្រុមសន្សំប្រាក់ | ទទួលបានភាគលាភ ពីក្រុមសន្សំប្រាក់ជារៀងរាល់ចុងឆ្នាំ | ២២,៥០ | | ២០២០ | ២០២២ | |
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជន) | សហគមន៍នេសាទទទួលបានកញ្ចប់ថវិកាពីប្រភពស្របច្បាប់ផ្សេងៗ | | | ២០២០ | ២០២២ | |
| ង.ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ | រៀបចំមហាសន្និបាតប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិច និងអ្នកពាក់ព័ន្ធ | -បានប្រជុំមហាសន្និបាត ១ដង/ឆ្នាំ<br>-ធ្វើសេចក្តីរាយការណ៍ពីលទ្ធផលការងារ និងលើកផែនការបន្ត | ៣០០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរមូលដ្ឋាន | ២០២០ | ២០២២ | |

## តារាងកម្មវិធីការងាររយៈពេល៣ឆ្នាំ (២០២០ - ២០២២)

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទ និងប្រភេទឧបករណ៍នេសាទហាមឃាត់ | | × | | | | | | × | | | | | × | | | | | | | × | | | | | × | | | | | | | × | | | | |
| ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផលិត និងបោះបង្គោលព្រំ | | | | × | × | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | |
| តម្លើងផ្ទាំងប៉ាណូផែនទីសហគមន៍ នេសាទចំនួន២ផ្ទាំង | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ស្លាកអប់រំនៅសហគមន៍ | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.៣.ផែនការកំណត់ និងរៀបចំតំបន់អភិរក្សអន្លង់យាយកែវ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងសារៈប្រយោជន៍ | | | | | | | × | | | | | | | × | | | | | | | × | | | | | | × | | | | | | × | | | |
| ដាក់ទង់សម្គាល់កន្លែងអភិរក្ស និងដាក់ស្លាកសញ្ញា | | | | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | |
| ចុះល្បាតការពារជាប្រចាំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ឃ.១.៤. ផែនការគ្រប់គ្រង ការពារព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយអោយបានទូលំទូ | | | | | × | | | | | | | | × | | | | | | × | | | | | | × | | | | | × | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| លាយពីសារៈប្រយោជន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹកចំនួន ២០ស្លាក | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចុះល្បាតការពារជាប្រចាំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| **ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | | | | | | × | × | | | | | | | | | | | × | × | | | | | | | | | | × | × | | | |
| បង្កើតធនាគារក្របីក្នុងស/ហ | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | | | | | | | | | × | × | | | | | | | | | | | | × | × | | | | | | | | | | |
| ដាំបន្លែតាមបច្ចេកទេសកសិកម្មវ័យឆ្លាត | × | × | | | | | | | | × | × | × | × | | | | | | | | | | | × | × | × | × | | | | | | | | × | × |
| បង្កើតក្រុមសន្សំប្រាក់១ក្រុម | | | | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ពង្រឹងធនាគារស្រូវក្នុងស/ហ | | | | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រីអណ្តែងក្នុងស្រះលក្ខណៈគ្រួសារ | | | | | | | | × | × | × | × | × | × | | | | | | | × | × | × | × | × | × | | | | | | × | × | × | × | × | |
| **ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បង្កើតឡជីវឧស្ម័នដល់សមាជិក | | | | | | × | × | × | × | | | | | | | | | | | | | × | × | × | × | × | × | | | | | | × | × | × | × |
| សាងសង់បង្គន់អនាម័យ | | | | | | | | | | | × | × | × | | | | | | | | | | | | | | | | × | × | × | × | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| សាងសង់អណ្តូងស្នប់ | | | | | | | | | | | | | | | | × | × | × | | | | | | | | | | × | × | × | | | | | | |
| ផ្តល់ធុងចម្រោះទឹក១០០ធុង | | | | × | × | | | | | | | | | | | × | × | | | | | | | | | | | × | × | | | | | | | |
| ផ្តល់បន្ទះសូឡាដល់សមាជិកសហគមន៍នេសាទ | | | | | | | | | | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | |
| ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួល អាកាសធាតុ និងការបង្ការផ្សេងៗ | | | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំបង្គោលវាស់កម្ពស់ទឹក | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| កំណត់រៀបចំទីទួលសុវត្ថិភាព | | | | | | | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | |
| ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិនិងចងក្រងបណ្តាញក្រុមទ្រទ្រង់គ្រោះមហន្តរាយ | | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការបន្សាំការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | × | × | × | | | | | | | | | | | | | | | | | | | | | | |
| ឃ.៣. ការងារគ្រប់គ្រង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សហគមន៍ចុះល្បាតដោយខ្លួនឯង | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ទិញទូកស្នាច់ម៉ាស៊ីន | | | × | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រេងសម្រាប់ល្បាត | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| សាងសង់ទីស្នាក់ការសហគមន៍នេសាទ | | | | | | | | | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | |
| ឃ.៣.២. ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| បណ្តុះបណ្តាលការរៀបចំរបាយការណ៍ កំណត់ហេតុ | | | | | | | × | | | | | | | | | | | | | | | | × | | | | | | | | × | | | | | |
| បណ្តុះបណ្តាលអំពីការគ្រប់គ្រងថវិកា | | | | | | | | | | | × | | | | | | | | | × | | | | | | | | | | × | | | | | | |
| បណ្តុះបណ្តាលអំពីរបៀបសរសេរគម្រោងសំណើរ | | | | | | | | | | | | | | | | | | | | | | | | | × | | | | | | | | | | | |
| ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | | | | | | × | | | | | | | | | | | | | | | | | | | | | × | | | | | | | | | |
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទ | × | | | | | | | × | | | | | | × | | | | | | × | | | | | | | × | | | | | | × | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| បញ្ហាផ្ទៃក្នុងសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | × | | | | | | | × | | | | | | × | | | | | | × | | | | | | | × | | | | | | × | | | |
| ផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | | | | | | | × | | | | | | | | | | | | | × | | | | | | | | | | × | | | | | | |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល និងចុះប្រមូលឧបករណ៍នេសាទខុសច្បាប់ និងដុតបំផ្លាញចោល | | | | | | | × | | | | | | | | | | | | | × | | | | | | | | | | × | | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ: សមភាពនិងសមធម៌យេនឌ័រ | | | | | × | | | | | | | | | | | | | | | | | × | | | | | | | | × | | | | | | |
| ឃ.៣.៤.ផែនការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន សន្និបាតប្រចាំឆ្នាំ | | | × | | | | | | | | | × | | | | | | | | | × | | | | | | | | × | | | | | | | |
| បញ្ចូលផែនការគ្រប់គ្រង | | | | | | | | | | × | × | × | | | | | | | | | | | × | × | × | | | | | | | | | × | × | × |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| កន្លែងនេសាទសហគមន៍ទៅក្នុងកម្មវិធីវិនិយោគឃុំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ភាគទានពីសមាជិក | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ភាគទានប្រចាំឆ្នាំពីសមាជិក | | | | × | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | |
| ប្រាក់បដិភាគអ្នកនេសាទខាងក្រៅសហគមន៍ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ប្រាក់បដិភាគអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| បដិភាគពីក្រុមសន្សំប្រាក់ | | | | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាលជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងពីសប្បុរសជន) | | | | × | | | | | | | | | | | × | | | | | | | × | | | | | | | | × | | | | | | |
| ង.ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិច និងអ្នកពាក់ព័ន្ធ | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | | | | | × | |

សូមគោរពជូន
លោកមេឃុំសៀមបូក
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ......ខែ......ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ភូមិទន្លេរាង,ថ្ងៃទី១៤...ខែ...ឆ្នាំ២០១៩
ប្រធានគណៈកម្មការសហគមន៍នេសាទទន្លេរាង

ព្រំ ចោម

លេខ០៦៥/១៩
បានឃើញ និងបញ្ជូនមក
លោកនាយផ្នែករដ្ឋបាលជលផលថាឡាបរិវ៉ាត់
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ......ខែ......ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
សៀមបូក,ថ្ងៃទី១៦...ខែ......ឆ្នាំ២០១៩
មេឃុំសៀមបូក

ធុំ សារុំ

លេខ៣៤...៩/១៩
បានឃើញ និងបញ្ជូនមក
លោកនាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ......ខែ......ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
......,ថ្ងៃទី១៥ខែ......ឆ្នាំ២០១៩
ជ.នាយផ្នែករដ្ឋបាលជលផលថាឡាបរិវ៉ាត់

លេខ០៤៣/...១៩
បានឃើញ និងគោរពជូន
លោកប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ......ខែ......ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ស្ទឹងត្រែង ថ្ងៃទី......ខែ......ឆ្នាំ២០១៩
នាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង

ទុំ នីរ៉ូ

លេខ...១៦...ក.ក.ស
បានឃើញ និងគោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
"ដើម្បីពិនិត្យ និងសម្រេចដោយអនុគ្រោះ"
ថ្ងៃ......ខែ......ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ស្ទឹងត្រែង ថ្ងៃទី២៣......ខែ......ឆ្នាំ២០១៩
ប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

លៀង_សេង

លេខ១៧៧ ជ.ជ
បានឃើញ និងឯកភាព
ថ្ងៃ......ខែ......ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ,ថ្ងៃទី១៧...ខែ......ឆ្នាំ២០២០
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

អេង ជាសាន